PORTLAND PUBLIC SCHOOLS
prepared & empowered

# *សេចក្តីយល់ព្រម របស់មាតាបិតាសិស្សក្នុងការប្រើប្រាស់ Parent Portal នៃសាលាសាធារណៈភតឡែន*

ការបើកមើល Internet និង secure web បានផ្លាស់ប្តូរមធ្យោបាយជាច្រើន ដែលដំណឹងសម្ងាត់ផ្ទាល់ខ្លួនត្រូវគេបើកមើលបាន ទាក់ទងគ្នា និងបញ្ជូនទៅកន្លែងផ្សេងៗ ។ ការផ្លាស់ប្តូរ ទាំងឡាយនោះកំពុងតែបានបំពាក់បំប៉ន ដល់ការបង្រៀន និងការសិក្សា របស់សិស្ស ។ ការបើកគេហៈទំព័រ ដោយសិស្សសាលា មាតាបិតា-អ្នកអាណាព្យាបាល លោកគ្រូ-អ្នកគ្រូ និងថ្នាក់ដឹកនាំសាលា ដើម្បីទទួលបាន នូវពត៌មានទាំងឡាយ ដែលអាចមានការ រីកចម្រើនក្នុងការចូលរួមជាមួយនិងការសិក្សា របស់ក្មេង និងធ្វើឱ្យប្រសើរឡើងវិញ ក្នុងការទាក់ទងរវាងសិស្សសាលា មាតាបិតា-អ្នកអាណាព្យាបាលសិស្ស និងគ្រូ របស់សិស្ស ។ សាលាសាធារណៈភតឡែនតែងរៀបចំទុកដាក់ជា electronic ហើយនិងធ្វើសំណៅសិក្សា របស់សិស្សឱ្យគេមើល ចំពោះមាតាបិតា-អ្នកអាណាព្យាបាលទាំងឡាយណា ដែលបានទទួលការអនុញ្ញាតជាមុនដោយមានសុវត្ថិភាពនៅក្នុង Internet ។ គ្រប់មាតាបិតា-អ្នកអាណាព្យាបាលសិស្ស នឹងត្រូវគោរពតាមបទវិន័យ នៃការប្រើប្រាស់ Internet និងគ្រប់បទវិន័យនិងនីតិវិធី របស់គ្រឿងនិងវិជ្ជាបច្ចេកទេស ក៏ដូចជាបទវិន័យសង្កាត់ឧទៃទៀត ទាំងអស់ផងដែរ ។

ក) សិទ្ធិ និង ការទទួលខុសត្រូវ

ការចូលមើលនេះ គឺជាសេវាមិនយកកម្រៃ ផ្តល់ជូនចំពោះមាតាបិតា-អ្នកព្យាបាលសិស្សនិងសិស្ស ដែលកំពុងតែសិក្សាក្នុងសាលារបស់យើង ។ ការបើក មើលដំណឹងសិស្ស គឺជាការអនុញ្ញាត មិនមែនជាសិទ្ធិរបស់អ្នកឡើយ ។ មាតាបិតា-អ្នកអាណាព្យាបាលសិស្ស នឹងត្រូវបានអនុញ្ញាតឱ្យ ធ្វើឱ្យសកម្ម នូវលេខ account របស់ខ្លួន បន្ទាប់ពីគ្រួសារនោះ បានចុះឈ្មោះកូន របស់ពួកគេ នៅក្នុងសាលាសាធារណៈភតឡែន ។ នៅពេលណា ដែលសិស្សដកខ្លួន ចេញឬបញ្ចប់ការសិក្សាពីសាលាសាធារណៈហើយនោះការអនុញ្ញាតឱ្យមើល Internet សាលាក៏ត្រូវបានដកហូតវិញដែរ ។ មាតាបិតា-អ្នកព្យាបាល សិស្សសិស្សសាលា និងបុគ្គលិកត្រូវយល់និងអនុវត្តន៍យ៉ាងត្រឹមត្រូវនិងប្រកបដោយសុជីវធ៌មប្រើប្រាស់ ។

ខ) ការទទួលខុសត្រូវចំពោះដំណឹងពិត

ដំណឹងពិតប្រាកដ របស់សិស្សគឺជាការទទួលខុសត្រូវរួម រវាងសាលារៀន **មាតាបិតា-អ្នកព្យាបាល** និងសិស្សគ្រប់រូប ។ សង្កាត់នឹងព្យាយាមគ្រប់ជំហាន ដើម្បីធានាថា ដំណឹងទាំងនោះបានលាតត្រដាង

នូវការពិតនិងចប់ចុងចប់ដើម ។ ប្រសិនបើមាតាបិតា-អ្នកព្យាបាលសិស្សបានរកឃើញថា មានដំណឹងណាមួយមិនត្រឹមត្រូវនោះ ពួកគេនឹងជម្រាបដល់សាលាពួកគេជាបន្ទាន់ ហើយដំណឹងត្រឹមត្រូវនោះមកផង ។

**គ) ភាពងាយស្រួលផ្លាស់ប្តូរដំណឹងសិស្ស**

សាលាសាធារណៈភតឡែន ប្រកាន់ភ្ជាប់នូវសិទ្ធិ របស់ខ្លួន ក្នុងការបន្ថែម កែសម្រួល ឬលប់បំបាត់ប្រអប់ចំណងជើង **functions** ណាមួយ តាមរយៈ **Internet site** នៅពេលណាមួយបាន មិនបាច់ជូនដំណឹងជាមុន រួមមាន ដោយគ្មានកំណត់ទៅលើ **functions** ទាំងអស់ដូចតទៅនេះ

1) វត្តមានសិស្សសាសា
2) តារាងកាលវិភាគ
3) វិញ្ញាសា
4) របាយការណ៍
5) កិច្ចការសិស្ស (ថ្នាក់អនុវិទ្យាល័យនិងវិទ្យាល័យ)
6) លិខិតដាក់ពាក្យសុំបើកមើល **Infinite Campus** សម្រាប់មាតាបិតា-អ្នកព្យាបាលសិស្ស

**ឃ) លិខិតដាក់ពាក្យសុំបើកមើល Infinite Campus សម្រាប់មាតាបិតា-អ្នកព្យាបាលសិស្ស**

**មាតាបិតា-អ្នកអាណាព្យាបាលសិស្សនិមួយៗ ត្រូវបំពេញ លិខិតដាក់ពាក្យសុំបើកមើល Infinite Campus សម្រាប់មាតាបិតា-អ្នកព្យាបាលសិស្ស មុននឹង គេអនុញ្ញាតឱ្យចូលមើលបាន ។ សូមមើលលិខិតភ្ជាប់មកជាមួយនេះ**

**ង) ការប្រើប្រាសប្រព័ន្ធផ្សប់ផ្សាយ**

**មាតាបិតា-អ្នកព្យាបាលសិស្ស គោងប្រកាន់ជាប់ តាមការណែនាំ ដូចតទៅនេះ:**

1) **មាតាបិតា-អ្នកព្យាបាលសិស្ស អនុវត្តក្នុងនាមជាអ្នកទទួលខុសត្រូវ មានសុជីវធម៌ និងស្របទៅតាមច្បាប់ ។**
2) **មាតាបិតា-អ្នកព្យាបាលសិស្ស នឹងមិនព្យាយាមបង្ខូចរបស់របរឬបំផ្លេចបំផ្លាញទិន្នន័យឬ networks របស់សាលារៀនឬសង្កាត់នោះឡើយ ។**

3) **មាតាបិតា-អ្នកព្យាបាលសិស្ស នឹងមិនព្យាយាមមើលដំណឹងឬលេខ**account **ដែលគេចេញឱ្យទៅអ្នកដទៃប្រើឡើយ ។**

**4)** **មាតា**បិតា-អ្នកព្យាបាលសិស្ស នឹងមិនប្រើ Internet site នេះ សម្រាប់ចលនាមិនស្របច្បាប់ រួមមានទាំងការល្មើសនិងច្បាប់ Data Privacy laws របស់សហរដ្ឋនិងរដ្ឋ ។ នរណាម្នាក់ ដែលរកឃើញថា បានល្មើសនិងច្បាប់ទាំងនោះ នឹងប្រឈមមុខទទួលខុសត្រូវទៅតាមច្បាប់ស៊ីវិល ក៏ដូចជា ព្រហ្មទណ្ឌ ។

**5)** មាតាបិតា-អ្នកព្យាបាលសិស្ស ដែលឃើងថា មានធ្លាយការសម្ងាត់ណាមួយនៅក្នុង**Portal**ត្រូវតែជូនដណឹងនេះទៅសាលារបស់ខ្លួនជាបន្ទាន់ ដោយមិន បង្ហាញបញ្ហានោះទៅអ្នកដទៃ ។

**6)** មាតាបិតា-អ្នកព្យាបាលសិស្ស នឹងមិនបង្ហាញលេខសម្ងាត់ **password** ទៅអ្នកដទៃ សូម្បីតែកូនទាំងឡាយ របស់ពួកគេ ។

**7)** មាតាបិតា-អ្នកព្យាបាលសិស្ស នឹងមិនរៀបចំកំព្យូទ័រ របស់ពួកគេឱ្យ **login** ស្វ័យប្រវត្តិនៅក្នុង **Internet site** ឡើយ ។

**8)** មាតាបិតា-អ្នកព្យាបាលសិស្ស ដែលត្រូវបានគេសម្គាល់ថា ជាមនុស្សមិនមានសុវត្ថិភាព នឹងត្រូវគេផ្អាកការប្រើប្រាស់គេហ:ទំព័រតទៅទៀតហើយ។

## ច) សន្តិសុខនានា មានដូចជា

**1)** **ការ**បើកមើល មានឱ្យប្រើប្រាស់ ជាមួយនិងសន្តិសុខ secure Internet site ។ អ្នកកាន់កាប់លេខ account ត្រូវមានការទទួលខុសត្រូវ ដោយមិនចែករំលែក passwords របស់ខ្លួន ហើយការពារវាបានល្អ ឬមិនបំផ្លាញរបស់របរបោះពុម្ព-អ៊ីឡិកត្រូនិកណាមួយ ដែលបានមកអំពី site នេះ ។

**2)** ការព្យាយាម **login** ៣ដងមិនបានសម្រេច គេនឹងបិទលេខ **account** បណ្តោះអាសន្នសិន ។ លេខ **account** នេះនឹងត្រូវរហូត ទាល់តែសង្កាត់ បានរកឃើងថា អ្នកពិតជាម្ចាស់ របស់លេខ **account** នោះមែន ។ ដើម្បីអ្នកអាចបើកលេខ **account** នេះបានវិញនោះ អ្នកត្រូវការអ៊ីម៉េលទៅ សាលារៀន របស់អ្នក ។ មាតាបិតា មានកូនចូលសាលារៀនពី២ឡើងទៅ ត្រូវការអ៊ីម៉េលទៅតែសាលាតែមួយប៉ុណ្ណោះ ជាការស្រេចទៅហើយ ។

3) អ្នកប្រើប្រាស់ទាំងឡាយ នឹងត្រូវគេបិទ **logged off** ជាស្វ័យប្រវត្តិ បើពួកបើកចោលនិងមិនប្រើប្រាស់ក្នុងរយៈពេលវែងបង្គួរ ។

4) លេខ **account** របស់មាតាបិតា-អ្នកអាណាព្យាបាល នឹងត្រូវគេបិទ ពេលណាកូនទាំងអស់ របស់គេបោះបង់ការសិក្សាឬបញ្ចប់ការសិក្សា ពីសាលារៀនភតឡែន ឬ មានដីការចៅក្រមហាមប្រាមបើកមើលដំណឹង របស់សិស្ស ។

## ឆ) ការទទួលខុសត្រូវ របស់សង្កាត់ មានកម្រឹត

សាលាសាធារណៈភតឡែន នឹងថ្លឹងថ្លែង ដោយមានហេតុផលសមរម្យ ដើម្បីការពារដំណឹងសិស្ស អំពីការបើកមើលណាមួយ ដែលគ្មានការអនុញ្ញាត ។ សង្កាត់នេះ នឹងមិនទទួលខុសត្រូវខាងទឹកប្រាក់ ដែលកើតមានឡើង ដោយអ្នកប្រើប្រាស់ District's system **ឬ** Internet គ្មានការអនុញ្ញាត ។ សង្កាត់ មិនបានសន្យាភាគណាមួយឬមធ្យោបាយ នៃការចូលមើលតាម Internet site អំពីដំណឹង របស់សិស្សសាលាទេ ។ សង្កាត់នេះ នឹងមិនទទួលខុសត្រូវ ចំពោះទង្វើទាំងឡាយណា ក្នុងការសម្របសម្រួលដុស្សេ របស់សិស្ស ។ សង្កាត់ប្រកាន់ជាប់ នូវសិទ្ធិ ដើម្បីកម្រឹតនិងបិទចោល នូវ Internet site ដើម្បីមើលដុស្សេ របស់សិស្ស ដោយការមិនជូនដំណឹងជាមុន ។ គ្រប់មាតាបិតា-អ្នកអាណាព្យាបាលសិស្ស ដែលប្រើប្រាស់ parent portal ដើម្បីមើលដុស្សេ របស់កូនខ្លួន ត្រូវបានអនុញ្ញាតឱ្យគេតាមដានខ្លួន តាមអ៊ីឡិកត្រូនិក ហើយនិងយល់ថា នេះគ្រាន់តែជាប្រព័ន្ធnetworkមួយ ប្រើប្រាស់ជាគ្រឿង សិក្សា ដោយបុគ្គលិកសាលារៀន ។ សកម្មភាព របស់ account **និ**មួយៗ ត្រូវបានគេថតទុកជាអ៊ីឡិកត្រូនិក ។

## ជ) ការទទួលជំនួយ

សូមអាន បើសិនជាលេខ account របស់អ្នក ត្រូវបានគេបិទ បន្ទាប់ពីព្យាយាមបើកបីលើក មិនបានសម្រេច ។ វិធីនេះ អាចចំណាយពេល២-៣ថ្ងៃ ពេលសាលាធ្វើការធម្មតា ។

- មាតាបិតា-អ្នកអាណាព្យាបាលសិស្ស ត្រូវធ្វើសំណូមពរបើកលេខ **account** ឡើញវិញ ដោយផ្ញើអ៊ីម៉េលទៅសាលាតែមួយប៉ុណ្ណោះ ។ ចំពោះ មាតាបិតា ដែលមានកូនក្នុងសាលាលើសពីមួយឡើងទៅ សូមផ្ញើទៅសាលាលំដាប់ខ្ពស់តែមួយបានហើយ ។
- សម្រាប់ការឆែកឆេរ លេខ account របស់អ្នក លេខអ៊ីម៉េល របស់អ្នក ត្រូវតែដូចគ្នានិងលេខអ៊ីម៉េលអ្នក ដែលយើងមាននៅសាលារៀន ។

- កាលណាសង្កាត់បានបញ្ជាក់នាម របស់មាតា-អ្នកអាណាព្យាបាលត្រឹមត្រូវហើយ លេខ **account** នឹងត្រូវបានបើកឱ្យប្រើប្រាស់ឡើងវិញ ។

**P29- KHM IC Parent Portal Agreement (updated 2-9-16)**

**PORTLAND PUBLIC SCHOOLS**
**លិខិតដាក់ពាក្យសុំប្រើប្រាស់ INFINITE CAMPUS PARENT/GUARDIAN PORTAL**
**របស់មាតាបិតាសិស្សសាលា**

សាលាសាធារណៈភតឡែន អាចផ្តល់ការបើកមើលដុស្សេសិស្ស តាមរយៈ Campus Portalបាន ។ ដើម្បីការពាររឿងអាថ៌កំបាំង របស់សិស្ស គ្រប់មាតាបិតា-អ្នកអាណាព្យាបាលសិស្ស ដែលចង់ប្រើប្រាស់សេវានេះ ត្រូវបានគេតម្រូវឱ្យបំពេញពាក្យ ហើយផ្ញើទៅវិញជាមួយនិងលិខិត តម្រូវដទៃទៀត ទៅសាលាតែមួយ របស់កូនពួកគេ ។

កំណត់សម្គាល់: សូមបំពេញលិខិតតែមួយ ក្នុងចំណោមលិខិតទាំងឡាយនោះ
លោកអ្នកនឹងអាចបើកមើលសំណុំរឿង របស់កូនអ្នក នៅគ្រប់សាលារៀន
ក្នុងសាលារៀនភតឡែននេះទាំងមូល ។
បើបច្ចុប្បន្ននេះ អ្នកមាន portal access ហើយនោះ មិនចាំបាច់បំពេញលិខិតនេះទេ ។

<u>សូមសរសេរសេរឈ្មោះ</u>

- នាមមាតាបិតា-អ្នកអាណាព្យាបាល: *(សូមបំពេញលិខិតមួយច្បាប់ សម្រាប់មនុស្សម្នាក់)*

______________________________________________

- លេខអាស័យដ្ឋាន របស់មាតាបិតា-អ្នកអាណាព្យាបាល:

______________________________________________

- លេខអ៊ីម៉េល របស់មាតាបិតា-អ្នកអាណាព្យាបាល: (បើគ្មានអ៊ីម៉េល សូមជួលទៅការិយាល័យសាលារៀន)

______________________________________________

*ខ្ញុំសូមបញ្ជាក់ថា គ្រប់ដំណឹងខាងលើនេះ មានភាពពិតប្រាកដ ហើយខ្ញុំមានសិទ្ធិពេញច្បាប់ ដើម្បីមើលសំណៅសិក្សាទាំងឡាយ របស់កូនខ្ញុំ ។*

ចុះហត្ថលេខា:_________________________________________ កាលបរិច្ឆេទ: ____________________

*ហត្ថលេខា* មាតាបិតា-អ្នកអាណាព្យាបាល *(ខែ_ថ្ងៃ_ឆ្នាំ)*

<u>សំខាន់</u> – កាលណា ដំណឹងបានផ្តល់មកយើងខាងលើបញ្ជាក់ត្រឹមត្រូវហើយ អ្នកនឹងអ្នកនឹងបានទទួល នូវ Activation Key តាមរយៈអ៊ីម៉េល ។ ពេលណា អ្នកបានទទួល Activation Key នេះហើយ អ្នកនឹងអាច sign up ចូលទៅក្នុង Parent Portal បានហើយ ។ សូមធ្វើតាមការណែនាំ ដែលផ្ញើមកអ្នកឬក៏យើងបិទផ្សាយនៅទីនេះ: http://www2.portlandschools.org/parents

| |
|---|
| <u>Office Use Only</u>:<br>Date Returned: ____________________ ❑ Verified Email Address ❑ Verified Home Address<br>❑ GUID Emailed ❑ GUID given by hand |